# ជីវប្រវត្តិសង្ខេបរបស់ចៅក្រម សហព្រះរាជអាជ្ញា មេធាវីការពារក្តី និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ការប្រកាស សាលដីកាលើបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅ អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០១២

---

អង្គជំនុំជម្រះតុលាការកំពូលមានសមាសភាពចៅក្រមដូចខាងក្រោម ៖



**ឯកឧត្តម គង់ ស្រ៊ីម (កម្ពុជា)៖** ត្រូវបានតែងតាំងជាប្រធានអង្គជំនុំជម្រះតុលាការកំពូល និងជាចៅក្រមជាតិប្រចាំការនៅ អ.វ.ត.ក ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០០៦។ មុនពេលចូលកាន់ទទួលតួនាទីនេះ គាត់ធ្លាប់មានតួនាទីជាច្រើន រួមមាន អនុប្រធានតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា អគ្គព្រះរាជអាជ្ញារងនៃការិយាល័យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអនុប្រធានការិយាល័យអយ្យការនៃនាយកដ្ឋានកិច្ចការព្រហ្មទណ្ឌនិងស៊ីវិលនៃក្រសួងយុត្តិធម៌ និងជាមន្ត្រីក្រសួងយុត្តិធម៌។ គាត់ក៏ជាសាស្ត្រាផ្នែកច្បាប់នៅសាកលវិទ្យាល័យនានាក្នុងទីក្រុងភ្នំពេញផងដែរ។ គាត់បានទទួលបរិញ្ញាប័ត្រច្បាប់ពីមហាវិទ្យាល័យច្បាប់នៃសកលវិទ្យាល័យទីក្រុងហូជីមិញ ប្រទេសវៀតណាម។



**លោកចៅក្រម ម៉ូតូ ណូហ្គូឈី (Motoo Noguchi)(ជប៉ុន)៖** មានបទពិសោធន៍វិជ្ជាជីវៈជាអ្នកច្បាប់ជាង ២៥ ឆ្នាំ។ លោកធ្លាប់ជាព្រះរាជអាជ្ញានៅប្រទេសជប៉ុន សាស្ត្រាចារ្យនៅវិទ្យាស្ថានស្រាវជ្រាវនិងបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌ មេធាវីប្រចាំនៅធនាគារអភិវឌ្ឍន៍អាស៊ី សាស្ត្រាចារ្យនៅវិទ្យាស្ថានអង្គការសហប្រជាជាតិនៅអាស៊ីនិងចុងបូព៌ា

សម្រាប់ទប់ស្កាត់ឧក្រិដ្ឋកម្មនិងការប្រព្រឹត្តិចំពោះចារី មេធាវីជាន់ខ្ពស់ប្រចាំការិយាល័យកិច្ចការច្បាប់អន្តរជាតិក្នុងក្រសួងការបរទេស សាស្ត្រាចារ្យជាន់ខ្ពស់បង្រៀននៅកម្មវិធីក្រោយឧត្តមសិក្សានៅសាកលវិទ្យាល័យតូក្យូ។ លោកទទួលបានបរិញ្ញាប័ត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យតូក្យូនៅឆ្នាំ១៩៨៣។ លោកមានទំនាក់ទំនងជាមួយសាលាច្បាប់នៃសាកលវិទ្យាល័យវ៉ាស៊ីនតោនពីឆ្នាំ១៩៩២-១៩៩៣ នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅឆ្នាំ២០០៥ មជ្ឈមណ្ឌល ស្សែល (Schell) ផ្នែកសិទ្ធិមនុស្សអន្តរជាតិនៃសាលាច្បាប់ យ៉េល (Yale) ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៧។ លោកបាននិពន្ធនិងបង្រៀនច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ជាច្រើននៅក្នុងប្រទេសជប៉ុននិងនៅបរទេស។



**លោកស្រីចៅក្រម អាញ៉េស្កា ក្លូណូវីកកា មីឡាត (Agnieszka Klonowiecka-Milart) (ប៉ូឡូញ)៖** បានចាប់ផ្តើមវិជ្ជាជីវៈច្បាប់ដោយបានបង្រៀនច្បាប់និងនីតិវិធីព្រហ្មទណ្ឌ នៅសាកលវិទ្យាល័យច្បាប់ក្នុងក្រុង លូប្លីន (Lublin) ប្រទេសប៉ូឡូញ។ លោកស្រីចាប់ផ្តើមបម្រើការនៅក្នុងស្ថាប័នតុលាការនៅឆ្នាំ១៩៩១ ហើយចាប់ពីពេលនោះមក លោកស្រីត្រូវបានជ្រើសតាំងជាច្រើនដងឲ្យធ្វើការនៅនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងច្បាប់អឺរ៉ុបនៃក្រសួងយុត្តិធម៌ប៉ូឡូញ ។ នៅក្នុងនាយកដ្ឋាននេះ លោកស្រីបានជួយធ្វើវិសោធនកម្មច្បាប់ និងកែទម្រង់ច្បាប់ឲ្យស្របគ្នានឹងបទដ្ឋានអន្តរជាតិ។ ចាប់ពីឆ្នាំ១៩៩៨ លោកស្រីបម្រើការនៅផ្នែកកំណែទម្រង់ច្បាប់និងតុលាការនៅក្នុងប្រទេសជាច្រើនដែលកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល រួមមាន ប្រទេសបូស្នៀ កូសូវ៉ូ និងអាហ្គានីស្ថាន។ ចន្លោះឆ្នាំ២០០០-២០០៧ លោកស្រីមានតួនាទីជាចៅក្រមអន្តរជាតិថ្នាក់កំពូល នៅក្នុងបេសកកម្មរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ។ នៅក្នុងបេសកកម្មនេះ លោកស្រីបានបំពេញការងារជាមួយនឹងសមាជិកផ្សេងៗទៀតក្នុងតុលាការជាតិ ដើម្បីវិនិច្ឆ័យទៅលើឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើភេរវកម្ម និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរជាច្រើនទៀត។



**លោកចៅក្រម ចាន់ដ្រា នីហាល ចាយ៉ាស៊ីងហេ (Chandra Nihal Jayasinghe) (ស្រីលង្កា)៖** ជាអតីតឧត្តមស្នងការស្រីលង្កាប្រចាំចក្រភពអង់គ្លេស និងជាអគ្គរដ្ឋទូតប្រចាំសាធារណរដ្ឋអៀរឡង់។ លោកធ្លាប់មានតួនាទីជាចៅក្រមជាន់ខ្ពស់ និងពេលខ្លះជាប្រធានចៅក្រមស្តីទីនៅក្នុងតុលាការកំពូលស្រីលង្កា។ លោកក៏ធ្លាប់ជា

ប្រធានសាលាឧទ្ធរណ៍ស្រីលង្កាផងដែរ។ លោកបានបម្រើការងារចំនួន២២ឆ្នាំ នៅក្នុងនាយកដ្ឋានអគ្គរដ្ឋអាជ្ញា ហើយការងាររបស់លោកភាគច្រើនទាក់ទងនឹងឧក្រិដ្ឋកម្ម ដោយនៅទីនោះលោកមានតួនាទីជាមេធាវីជាន់ខ្ពស់របស់រដ្ឋ ហើយក្រោយមកនៅឆ្នាំ១៩៩៤ គាត់បានក្លាយជាអគ្គទីប្រឹក្សារងផ្នែកច្បាប់។ លោក ចាយ៉ាងស៊ីងហេ បានទទួលបរិញ្ញាប័ត្រច្បាប់ពីសាកលវិទ្យាល័យកូឡុំបូ ជាសាស្ត្រាចារ្យទស្សនកិច្ចនៅសាកលវិទ្យាល័យ អ៊ីលីណយ ក្នុងរដ្ឋឈីខាហ្គោ និងបានទទួលសញ្ញាប័ត្រផ្នែកសិទ្ធិមនុស្សពីសាកលវិទ្យាល័យ លុន (Lund) នៃប្រទេសស៊ុយអែដ។



**លោកចៅក្រម សោម សិរីវឌ្ឍ (កម្ពុជា)**៖ មានបទពិសោធន៍ជំនាញតុលាការរយៈពេល២២ឆ្នាំ។ លោកចាប់ផ្តើមបម្រើការងារជាចៅក្រមក្នុងតុលាការកំពូលតាំងពីឆ្នាំ១៩៨៨មក។ ពីឆ្នាំ១៩៧៩ -១៩៨៦ លោកជាប្រធានស្តីទីនៃខុទ្ទកាល័យក្រសួងមហាផ្ទៃ ហើយពីឆ្នាំ១៩៨៦-១៩៨៨ លោកគឺជាមន្ត្រីក្នុងតុលាការកំពូល។ លោកធ្លាប់ចូលរួមក្នុងសិក្ខាសាលាជាច្រើននៅប្រទេសជប៉ុន ប្រទេសស្វីស និងទីក្រុងប៉ារីស។ លោកធ្វើជាគ្រូឧទ្ទេសនាមនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។ នៅឆ្នាំ២០០៥ លោកបានក្លាយជាសមាជិកក្រុមរៀបចំសេចក្តីព្រាងក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់ប្រទេសកម្ពុជា។



**បណ្ឌិត យ៉ា ណារិន (កម្ពុជា)**៖ បច្ចុប្បន្នជាប្រធានតុលាការខេត្តមណ្ឌលគិរី។ លោកចាប់ផ្តើមបម្រើការងារដំបូងក្នុងការិយាល័យតុលាការដំបូងនៅឆ្នាំ២០០១ និងទទួលបានការតែងតាំងជាចៅក្រមនៅតុលាការខេត្តរតនគិរីនៅឆ្នាំ២០០២ ហើយនៅឆ្នាំ២០០៥ បានក្លាយជាប្រធានតុលាការខេត្តនេះ។ មុននឹងទទួលតួនាទីខាងលើនេះ លោកធ្លាប់បម្រើការងារជាមន្ត្រីនៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី ទទួលខុសត្រូវសិក្សាសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានដែលស្នើឡើងដោយក្រសួងនានា។ លោកបានចាប់ផ្តើមសិក្សាផ្នែកច្បាប់នៅសាកលវិទ្យាល័យរដ្ឋកាហ្សាក់ (Kazakh) និងទទួលសញ្ញាប័ត្របណ្ឌិតឯកទេសឧក្រិដ្ឋវិទ្យា ពីវិទ្យាស្ថានរដ្ឋនិងច្បាប់នៃប្រទេសកាហ្សាក់ស្ថាន នៅឆ្នាំ១៩៩៨។



**បណ្ឌិត ស៊ីន រិទ្ធ (កម្ពុជា)៖** គឺជាអគ្គព្រះរាជអាជ្ញារងនៃការិយាល័យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ លោកបានសិក្សាច្បាប់អស់រយៈពេល ១០ ឆ្នាំ នៅសាធារណរដ្ឋកាហ្សាក់ស្ថាន និងបានទទួលសញ្ញាប័ត្របណ្ឌិតច្បាប់ពីសាកលវិទ្យាល័យជាតិកាហ្សាក់ស្ថាន នៅឆ្នាំ១៩៨៧។ លោកទទួលបានការតែងតាំងជាព្រះរាជអាជ្ញារងនៅតុលាការខេត្តបាត់ដំបងនៅឆ្នាំ២០០១ ហើយនៅឆ្នាំ២០០៥ លោកទទួលបានការតែងតាំងជាព្រះរាជអាជ្ញានាំមុខសម្រាប់តុលាការកំពូល។ លោកធ្លាប់ជាសមាជិកក្រុមរៀបចំសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីសម្រាប់ប្រទេសកម្ពុជា។ លោកជាសាស្ត្រាចារ្យច្បាប់ព្រហ្មទណ្ឌអន្តរជាតិនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ចៅក្រមបម្រុង



**លោក ម៉ុង មុន្នីចរិយា (កម្ពុជា)៖** ជាប្រធានចៅក្រមនៅសាលាដំបូងខេត្តព្រះសីហនុចាប់ពីឆ្នាំ២០០៩។ នៅឆ្នាំ១៩៩៦ លោកបម្រើការជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ហើយនៅឆ្នាំ២០០២ លោកត្រូវបានតែងតាំងជាចៅក្រមតុលាការកំពូល។ ក្នុងអំឡុងពេល១០ឆ្នាំចុងក្រោយនេះ លោកជាសមាជិកក្រុមកម្ពុជាទទួលខុសត្រូវធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីនិងក្រមនិតីវិធីរដ្ឋប្បវេណី ហើយចាប់ពីឆ្នាំ២០០៤ លោកគឺជាសាស្ត្រាចារ្យនៅសាលាភូមិន្ទចៅក្រម និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ពីសាកលវិទ្យាល័យជាតិកាហ្សាក់ស្ថាននៅ ឆ្នាំ១៩៩៣ និងជានិស្សិតស្រាវជ្រាវថ្នាក់បណ្ឌិតនៅសាកលវិទ្យាល័យបៀលប្រាយ។ នៅឆ្នាំ១៩៩៥ លោកបានទទួលសញ្ញាប័ត្រវិជ្ជាជីវៈចៅក្រម។ លោកក៏ធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលបានរៀបចំឡើងដោយទីស្តីការគណៈរដ្ឋមន្ត្រី សហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល សម្រាប់ស្ថាប័នយុត្តិធម៌នៅអាស៊ី និងវគ្គបណ្តុះបណ្តាលរបស់កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) នៅសាលាភូមិន្ទចៅក្រមនិងព្រះរាជអាជ្ញា។



**លោកស្រីចៅក្រម ហ្វ្លរេន មុមបា (Florence Mumba) (ហ្សំប៊ី)៖** ចាប់ផ្តើមបំពេញការងារក្នុងផ្នែកតុលាការចាប់ពីឆ្នាំ១៩៧៣។ លោកស្រីគឺជាស្ត្រីទីមួយដែលបានទទួលការតែងតាំងជាចៅក្រមនៅតុលាការជាន់ខ្ពស់នៅឆ្នាំ១៩៨០ និងជាប្រធានការិយាល័យស៊ើបអង្កេត។ ចាប់ពីឆ្នាំ១៩៩៧ លោកស្រីគឺជាចៅក្រមនៅតុលាការកំពូលនៃប្រទេសហ្សំប៊ី។ នៅឆ្នាំ១៩៩៧ លោកស្រីត្រូវបានជ្រើសរើសឲ្យធ្វើជាចៅក្រមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ក្នុងទីក្រុងឡាអេ និងក្លាយជាអនុប្រធាននៅតុលាការនេះ (ឆ្នាំ១៩៩៩-២០០១)។ ពីឆ្នាំ២០០៣-២០០៥ លោកស្រីបម្រើការជាចៅក្រមនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) និងនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់ដា (ICTR)។ ក្នុងឋានៈជាមេធាវីល្បីល្បាញម្នាក់និងជាសកម្មជនសិទ្ធិស្ត្រី លោកស្រីបានធ្វើដំណើរទៅទីកន្លែងជាច្រើនដើម្បីធ្វើបទបង្ហាញឯកសារស្រាវជ្រាវ និងបានការពារនីតិរដ្ឋក្នុងបញ្ហាអភិបាលកិច្ច ក្នុងឋានៈលោកស្រីជាអ្នកស៊ើបអង្កេតលើបណ្តឹងរបស់ពលរដ្ឋប្រឆាំងនឹងរដ្ឋាភិបាលឬអាជ្ញាធរសាធារណៈ។

## សហព្រះរាជអាជ្ញា



**លោកស្រី ជា លាង (កម្ពុជា)** ៖ ទទួលបានបរិញ្ញាប័ត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យ ម៉ាទីន លូថឺ (Martin Luther) នៅប្រទេសអាល្លឺម៉ង់ នៅឆ្នាំ១៩៩៥។ នៅឆ្នាំ១៩៩៦ លោកស្រីចាប់ផ្តើមវិជ្ជាជីវៈផ្នែកច្បាប់នៅក្រសួងយុត្តិធម៌ និងត្រូវបានដំឡើងឋានៈជាអនុប្រធានការិយាល័យបណ្តុះបណ្តាលនៃក្រសួងយុត្តិធម៌នៅឆ្នាំ១៩៩៩។ លោកស្រីបានចាប់យកអាជីពជាព្រះរាជអាជ្ញានៅសាលាឧទ្ធរណ៍នៃតុលាការកម្ពុជានៅឆ្នាំ២០០២ និងបានចូលរួមក្នុងដំណើរការកាត់ក្តីជាច្រើននៅសាលាឧទ្ធរណ៍ និងធ្វើអធិការកិច្ចលើការងាររបស់ព្រះរាជអាជ្ញានានានៅថ្នាក់ខេត្ត។ លោកស្រីបានទទួលការបណ្តុះបណ្តាលផ្សេងៗទៀតដូចជា៖ សិទ្ធិមនុស្សនៅប្រទេសដាណឺម៉ាក កិច្ចសហប្រតិបត្តិការច្បាប់ និងតុលាការនៅប្រទេសជប៉ុន និងការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌអន្តរជាតិនៅទីក្រុងឡាអេ ប្រទេសហុល្លង់។



**លោក អេនឌ្រូ ខេលី (Andrew CAYLEY) (អង់គ្លេស)**៖ ត្រូវបានតែងតាំងជាសហព្រះរាជអាជ្ញាអន្តរជាតិនៃ អ.វ.ត.ក ជំនួសលោក រ៉ូប៊ើត ប៉ីទី នៅខែធ្នូ ឆ្នាំ២០០៩។ ពីមុន គាត់ជារដ្ឋអាជ្ញាជាន់ខ្ពស់នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងទទួលបន្ទុករឿងក្តីដាហ្វួ (Darfur) ទីមួយ។ គាត់ក៏ធ្លាប់បម្រើការជារដ្ឋអាជ្ញា បន្ទាប់មកជារដ្ឋអាជ្ញាជាន់ខ្ពស់នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយ៉ូហ្គោស្លាវី។ គាត់ជាមេធាវីជាន់ខ្ពស់មួយរូបនៃគណៈមេធាវី អ៊ីនណឺ ថេមភល (Inner Temple) ហើយគាត់ទទួលបរិញ្ញាប័ត្រនិងសញ្ញាប័ត្រអនុបណ្ឌិតនីតិសាស្ត្រពីសាកលវិទ្យាល័យឡុងដ៍។ គាត់ក៏ជាមន្ត្រីជំនាញមួយរូបដែលបានបញ្ចប់ការសិក្សាពីរាជបណ្ឌិតសភាយោធា សាន់ហឺស (Sandhurst)។

## សហព្រះរាជអាជ្ញារង



**លោក យ៉េត ចរិយា (កម្ពុជា)** ៖ ចាប់អាជីពក្នុងវិស័យច្បាប់ដោយធ្វើជាក្រឡាបញ្ជីនៅតុលាការក្រុងភ្នំពេញនៅឆ្នាំ១៩៨០ ហើយនៅឆ្នាំ១៩៨៩ លោកត្រូវបានតែងតាំងជាព្រះរាជអាជ្ញារងនៅតុលាការក្រុងភ្នំពេញ។ នៅឆ្នាំ២០០៦ លោកបានផ្ទេរទៅបម្រើការជាព្រះរាជអាជ្ញារងនៅសាលាដំបូងខេត្តបន្ទាយមានជ័យ។ លោកមានបទពិសោធន៍ក្នុងការងារស៊ើបអង្កេតនិងការងារសវនាការរឿងក្តីព្រហ្មទណ្ឌ។ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកនីតិសាស្រ្តពីសាកលវិទ្យាល័យចំរើនពហុបច្ចេកវិជ្ជា។ ក្រៅពីនេះ លោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបន្ថែមផ្សេងៗអំពីនីតិវិធីតុលាការនិងច្បាប់ព្រហ្មទណ្ឌនៅប្រទេសថៃ និងសហរដ្ឋអាមេរិក។



**លោក វីលលៀម ស្មីត (អូស្រ្តាលី)** ៖ ធ្លាប់ជារដ្ឋអាជ្ញា ទីប្រឹក្សាច្បាប់ និងជាអ្នកវិភាគនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) អស់រយៈពេល១០ឆ្នាំ មុនពេលលោកចូលកាន់មុខតំណែងនៅ អ.វ.ត.ក។ មុននេះទៀត លោកជាប៉ូលីសរដ្ឋអាជ្ញានៅក្នុងកងកម្លាំងនគរបាលអូស្រ្តាលីខាងត្បូងអស់រយៈពេល៧ឆ្នាំ។ លោកបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យអាឌីឡែត (Adelaide) នៅឆ្នាំ១៩៩៣ ខណៈដែលលោកកំពុងបម្រើការងារនៅនាយកដ្ឋានអយ្យការនៅអូស្រ្តាលីខាងត្បូង ហើយបន្ទាប់មក ធ្វើជាស្នាក្តីផ្នែកច្បាប់ព្រហ្មទណ្ឌ និងជាមេធាវីជាន់ខ្ពស់នៅទីក្រុងអាឌីឡែត។ នៅឆ្នាំ១៩៩៩ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតច្បាប់អន្តរជាតិ ពីសាកលវិទ្យាល័យឡេដិន (Leiden)។ នៅឆ្នាំ២០០០ លោកបានទទួលឋានៈធ្វើជាមន្ត្រីទីពីរផ្នែកសិទ្ធិមនុស្សរបស់ អ.ស.ប ប្រចាំនៅប្រទេសទីម័រខាងកើត  ក្នុងតួនាទីជាប្រធានរដ្ឋបាលស្តីទីប្រចាំស្រុក។

## មេធាវីការពារក្តី



**លោកមេធាវី ការ សាវុត្ថ (កម្ពុជា)៖** បានប្រកបវិជ្ជាជីវៈលើវិស័យច្បាប់ព្រហ្មទណ្ឌ តាំងពីឆ្នាំ១៩៨២ លោកគឺជាមេធាវីទីមួយដែលត្រូវបានទទួលស្គាល់ជាសមាជិក គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ លោកបានធ្វើជាតំណាងឲ្យកូនក្តីជាច្រើន នាក់ដែលជាជនជាប់ចោទពីបទឧក្រិដ្ឋធ្ងន់ធ្ងរ រួមទាំងអតីតសមាជិកខ្មែរក្រហម ផងដែរ។ លោកក៏ធ្លាប់ជាទីប្រឹក្សាផ្នែកច្បាប់នៅអគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ។



**លោក កង ឬទ្ធារី (កម្ពុជា)៖** បានប្រកបវិជ្ជាជីវៈក្នុងវិស័យច្បាប់ព្រហ្មទណ្ឌចាប់ តាំងពីគាត់ចូលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០០២។ លោកក៏ជាប្រធាននៃក្រុមមេធាវីអាស៊ានអន្តរជាតិតាំងពីឆ្នាំ២០០២។ លោកបាន ទទួលសញ្ញាប័ត្របណ្ឌិតផ្នែកច្បាប់ និងបានបម្រើការជាសាស្ត្រាចារ្យច្បាប់តាំងពីឆ្នាំ ២០០៧។

## មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី



**លោក ការីម ខាន់ (Karim A. A. KHAN) (អង់គ្លេស)៖** មានបទពិសោធន៍ រយៈពេល១៦ឆ្នាំ ជាមេធាវីជាន់ខ្ពស់នៅក្នុងតុលាការជាតិនិងតុលាការអន្តរជាតិ។ លោកធ្លាប់ធ្វើជាអគ្គព្រះរាជអាជ្ញានៅស្ថាប័នគណៈកម្មការច្បាប់របស់ប្រទេសអង់គ្លេសនិងប្រទេសវែល។ លោកធ្លាប់បម្រើការនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) តុលាការពិសេសនៅប្រទេសទីម័រខាងកើត តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លោកជាសហអ្នកនិពន្ធសៀវភៅដែលមានចំណងជើងថា “តុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅ អាឆឺបូល” (Archbold International Criminal Courts)។



**លោកស្រី ទី ស្រ៊ីនណា (កម្ពុជា)** ៖ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យបញ្ញាសាស្ត្រ ជំនាញនីតិអន្តរជាតិនិងនីតិព្រហ្មទណ្ឌ។ លោកស្រីត្រូវបានទទួលស្គាល់ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ ២០០៧។ ចាប់តាំងពីពេលនោះមក លោកស្រីបានបំពេញការងារនៅអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) ការិយាល័យមេធាវី ប៉ាណាអេស៊ាន (Pana Asean Law Office) និងការិយាល័យមេធាវីអាស៊ីប៉ាស៊ីហ្វិកអន្តរជាតិ (Asia Pacific International Law Firm)។



**លោក អាឡែន វើនឺ (Alain Werner) (ស្វីស)៖** ជាសមាជិកនៃគណៈមេធាវីហ្សឺណែវ ចាប់តាំងពីខែមិថុនា ឆ្នាំ២០០២មក។ លោកបានធ្វើការងារផ្ទាល់ជាមួយជនរងគ្រោះក្នុងតួនាទីរបស់លោកជារដ្ឋអាជ្ញាអស់រយៈពេលជាច្រើនឆ្នាំមកហើយ នៅឯតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។ នៅថ្មីៗនេះ លោកគឺជាសមាជិកក្នុងក្រុមមួយនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស ដែលបំពេញការងារនៅក្នុងប្រទេសឆាដក្នុងគោលបំណងដើម្បីនាំយកជនផ្តាច់ការប្រទេសឆាដឈ្មោះ ហ៊ីសសិន ហាប្រេ

(Hissene Habre) ទៅកាត់ សេចក្តីនៅក្នុងប្រទេសសេណេហ្គាល់ (Senegal)។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកនីតិសាស្ត្រនៅ សាកលវិទ្យាល័យកូឡុំបៀ (Columbia) ជំនាញនីតិព្រហ្មទណ្ឌអន្តរជាតិ។



**លោកស្រី ប្រាយអាន មេហ្គោនីហ្គល (Brianne McGonigle) (សហរដ្ឋអាមេរិក)៖** គឺជាសមាជិកមួយរូបនៃគណៈមេធាវីរដ្ឋចចជៀ (Georgia) សហរដ្ឋអាមេរិក តាំងពីឆ្នាំ២០០៧។ លោកស្រីមានជំនាញខាងផ្នែកនីតិព្រហ្មទណ្ឌអន្តរជាតិ នីតិមនុស្សធម៌អន្តរជាតិ សិទ្ធិមនុស្ស និងសិទ្ធិរបស់ជនរងគ្រោះ។ ក្រៅពីស្នាដៃស្រាវជ្រាវថ្នាក់បណ្ឌិតរបស់លោកស្រីស្តីអំពី "ការចូលរួមរបស់ជនរងគ្រោះក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិ" លោកស្រីក៏មានបទពិសោធន៍ធ្វើការជាមួយក្រុមមេធាវីការពារក្តីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ហើយលោកស្រីក៏ជាមេធាវីទស្សនកិច្ចនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៃការិយាល័យពិគ្រោះយោបល់សាធារណៈសម្រាប់ជនរងគ្រោះ (Office of Public Counsel for Victims)។



**លោកស្រី ស៊ីលកេ ស្ទុដហ្សីនស្គី (Silke Studzinsky) (អាល្លឺម៉ង់)៖** បានប្រកបវិជ្ជាជីវៈជាមេធាវីការពារក្តីរឿងព្រហ្មទណ្ឌ និងជាអ្នកតំណាងសហដើមចោទនៅតុលាការអាល្លឺម៉ង់ អស់រយៈពេល១៧ឆ្នាំរួចមកហើយ។ ចាប់តាំងពីខែកុម្ភៈឆ្នាំ២០០៨ លោកស្រីបានធ្វើការនៅក្នុងក្របខណ្ឌសេវាកម្មសន្តិភាពស៊ីវិលរបស់អង្គការអភិវឌ្ឍន៍អាល្លឺម៉ង់ DED នៅប្រទេសកម្ពុជា និងជាតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងទាំងពីរនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។



**លោក ហុង គីមសួន (កម្ពុជា)៖** បានប្រកបវិជ្ជាជីវៈលើវិស័យច្បាប់ព្រហ្មទណ្ឌតាំងពីឆ្នាំ១៩៨៣ មក។ លោកត្រូវបានទទួលស្គាល់ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ១៩៩៩។ ចាប់ពីឆ្នាំ២០០៦ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ នៅឆ្នាំដដែលនេះ លោកក៏ត្រូវបានតែងតាំងជាប្រធានក្រុមមេធាវីសម្រាប់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជានៅទីក្រុងភ្នំពេញ។



**លោក គង់ ពិសី (កម្ពុជា)៖** បានចូលប្រឡូកក្នុងវិស័យច្បាប់ព្រហ្មទណ្ឌតាំងពីឆ្នាំ១៩៨៧ ហើយលោកត្រូវបានទទួលស្គាល់ជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៩៩។ បច្ចុប្បន្ននេះ លោកគឺជាប្រធានបច្ចេកទេសមេធាវីនៃក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជានៅទីក្រុងភ្នំពេញ។



**លោក យុង ផានិត (កម្ពុជា)៖** បានធ្វើសច្ចាប្រណិធានចូលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ១៩៩៧។ បច្ចុប្បន្ន លោកគឺជាអនុប្រធានក្រុមផ្តន្ទាទោសនៃក្រុមការងារថ្នាក់ជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស។



**កញ្ញា ម៉ុច សុវណ្ណារី (កម្ពុជា)៖** ត្រូវបានទទួលស្គាល់ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០០៨។ កញ្ញាបានប្រកបវិជ្ជាជីវៈលើវិស័យច្បាប់តាំងពីឆ្នាំ២០០៥។ នៅឆ្នាំ២០០៧ កញ្ញាមានតួនាទីជាទីប្រឹក្សាច្បាប់នៅ B.N.G - Avocats and Solicitors និងជាមេធាវីនៅ “ការិយាល័យមេធាវី ប៊ុនវ៉េង និងដៃគូ” (Bunveng Law Office and Partner)។ នៅឆ្នាំ២០០៨ កញ្ញាបានក្លាយជាសាស្ត្រាចារ្យច្បាប់ជំនួញនៅសាកលវិទ្យាល័យពុទ្ធិសាស្ត្រ។ បច្ចុប្បន្ននេះ កញ្ញាជាមេធាវីនៅ “ការិយាល័យមេធាវី ប៊ុនវ៉េង និងដៃគូ” និងក្រុមមេធាវីគ្មានព្រំដែន។



**លោក គីម ម៉េងឃី (កម្ពុជា)៖** បានប្រកបវិជ្ជាជីវៈលើវិស័យច្បាប់តាំងពីឆ្នាំ២០០៥ និងបានចូលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅឆ្នាំ២០០៨។ លោកធ្លាប់ធ្វើជាជំនួយការច្បាប់ និងជាអ្នកស្រាវជ្រាវនៅ*អង្គការតម្លាភាពអន្តរជាតិ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម* និង *វិទ្យាស្ថានគ្រប់គ្រងបរិស្ថិមបូព៌ា* និងជាទីប្រឹក្សាច្បាប់នៅការិយាល័យមេធាវី B.N.G-Avocats and Solicitors។ លោកគឺជាសាស្ត្រាចារ្យ

ច្បាប់នៅវិទ្យាស្ថានក្រុងអង្គរ និងសាកលវិទ្យាល័យដទៃទៀត។ នៅឆ្នាំ២០០៨ លោកគឺជាមេធាវីនៅ "ការិយាល័យ មេធាវី ប៊ុន វែង និងដៃគូ"។ បច្ចុប្បន្ននេះលោកគឺជាប្រធាននៃ "ការិយាល័យមេធាវី ឃីឌី" និងជាមេធាវីនៅក្នុងក្រុមមេធាវីគ្មានព្រំដែន។



**លោកស្រី ម៉ាទីន ហ្សាកាំង (Martine Jacquin) (បារាំង)៖** គឺជាសមាជិកគណៈមេធាវីប៉ារីសតាំងពីឆ្នាំ១៩៧៣។ នៅឆ្នាំ២០០៤ លោកស្រីគឺជាប្រធានមន្ត្រីកម្មវិធីនៃក្រុមមេធាវីគ្មានព្រំដែនប្រចាំនៅប្រទេសកម្ពុជា។ លោកស្រីបានចូលរួមដោយផ្ទាល់ក្នុងកម្មវិធីបណ្តុះបណ្តាលមេធាវីក្មេងៗ និងបានបង្កើតនូវបណ្តាញមេធាវីមិនយកកម្រៃ ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រក្នុងការចូលរួមក្នុងតុលាការកម្ពុជា។ បច្ចុប្បន្ន លោកស្រីគឺជាប្រធានការិយាល័យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលបង្កើតឡើងដោយក្រុមមេធាវីគ្មានព្រំដែនបារាំង។

**លោក ហ្វីលីព កាណុន (Philippe Canonne) (បារាំង)៖** ត្រូវបានទទួលស្គាល់ជាសមាជិកគណៈមេធាវីប៉ារីសនៅឆ្នាំ១៩៧៧។ បញ្ចប់ការសិក្សានៅឯមហាវិទ្យាល័យនីតិសាស្ត្រក្រុងប៉ារីស លោកគឺជាមេធាវីផ្នែកសិទ្ធិពលរដ្ឋ។ ក្នុងនាមជាប្រធាននៃគណៈមេធាវី អូរីឡាក់ (Aurillac) និងជាសមាជិកនៃក្រុមមេធាវីគ្មានព្រំដែនបារាំង បច្ចុប្បន្នលោកគឺជាសហអ្នកដឹកនាំក្រុមកម្ពុជា។ លោកគឺជាសាស្ត្រាចារ្យនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលមេធាវីនៅទីក្រុងភ្នំពេញ និងជាសាស្ត្រាចារ្យទស្សនកិច្ចនៅវិទ្យាស្ថានបណ្តុះបណ្តាលសិទ្ធិមនុស្ស។



**លោកស្រី អេលីហ្សាបេត ចូអេល រ៉ាបេសានដ្រាតាណា (Elisabeth-Joelle Rabesandratana) (បារាំង-ម៉ាដាហ្គាស្កា)៖** ប្រកបវិជ្ជាជីវៈក្នុងវិស័យច្បាប់នៅប្រទេសបារាំងតាំងពីឆ្នាំ១៩៧៦។ លោកស្រីមានជំនាញខាងរឿងក្តីព្រហ្មទណ្ឌ ហើយមានឈ្មោះក្នុងបញ្ជីមេធាវីនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ។ លោកស្រីក៏ជាសមាជិកសកម្មមួយរូបនៃក្រុមមេធាវីគ្មានព្រំដែន។